**Declassified to Public**
**12 June 2020**

លេខ៖ D200/4

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**Kingdom of Cambodia**
**Nation Religion King**

**Royaume du Cambodge**
**Nation Religion Roi**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

---

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**

**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 25-Jul-2014, 15:35
CMS/CFO: Sann Rada

**លេខសំណុំរឿង៖ ០០៤/០៧-០៩-២០០៩/អ.វ.ត.ក-ក.ស.ច.ស**

ចំពោះមុខ ៖ **សហចៅក្រមស៊ើបអង្កេត**

កាលបរិច្ឆេទ ៖ **ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១៤**

ភាសា ៖ **អង់គ្លេស**

ចំណាត់ថ្នាក់ឯកសារ ៖ **សម្ងាត់បំផុត**

---

# ដីកាសម្រេចទីបីលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំបង្ហាញនៅក្នុងសំណុំរឿង ០០២/០២ នូវអត្តសញ្ញាណរបស់សាក្សីមួយចំនួនដែលត្រូវបានស្តាប់ចម្លើយ នៅក្នុងសំណុំរឿង ០០៤

---

**<u>ផ្ញើជូន</u>**

**សហព្រះរាជអាជ្ញា**

ជា លាង

Nicholas KOUMJIAN

**បានឃើញ** ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៤ (“ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក”)។

**បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី៣ ដាក់នៅថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩[1]។

**បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់១ និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម ដាក់នៅថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១១[2]។

**បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាទាក់ទងនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ និងអំពើហិង្សាយេនឌ័រ ដាក់នៅថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៤[3]។

**បានឃើញ** ការបើកកិច្ចស៊ើបសួរទាក់ទងនឹងការចោទប្រកាន់អំពីការរំលោភបំពានក្រមព្រហ្មទណ្ឌ **ឆ្នាំ ១៩៥៦ អនុសញ្ញាស្តីពីការទប់ស្កាត់ និងផ្តន្ទាទោសចំពោះអំពើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ អនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ ១៩៤៩** និង**ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ** ដែលត្រូវផ្តន្ទាទោសតាមមាត្រា ៣(ថ្មី), ៤, ៥,៦, ២៩ និង៣៩ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ព្រមទាំងមាត្រា ២០៩, ២១០, ៥០០, ៥០១, ៥០៣, ៥០៤, ៥០៥, ៥០៦, ៥០៧, និង ៥០៨ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ ១៩៥៦។

**បានឃើញ**វិធាន ៥៥, ៧២ និង៨៧ នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក (“វិធានផ្ទៃក្នុង”)។

**បានពិចារណាទៅលើ** សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំបង្ហាញនៅក្នុងសំណុំរឿង ០០២/០២ នូវអត្តសញ្ញាណរបស់សាក្សីមួយចំនួនដែលត្រូវបានស្តាប់ចម្លើយនៅក្នុងសំណុំរឿង០០៤(“សំណើ”)[4]។

---

[1] សំណុំរឿង០០៤ ឯកសារ D1 *ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីពីររបស់សហព្រះរាជអាជ្ញា* ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨(“ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី ៣”)។ សំណុំរឿង០០៤ ឯកសារD1/1 *ការជូនដំណឹងអំពីការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីពីររបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី* ថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩។

[2] សំណុំរឿង ០០៤ ឯកសារ D65 *ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់ ១ និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម* ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១១។

[3] សំណុំរឿង ០០៤ ឯកសារ D191 *ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាទាក់ទងនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ និងអំពើហិង្សាយេនឌ័រ* ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៤។

**បានឃើញ** កំណត់ហេតុនៃករណីខ្វែងយោបល់គ្នាចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៣ ថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០១៣ និងថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៤។

## ឧទ្ទិករណ៍

១. ដោយអនុវត្តតាមសេចក្តីសម្រេចមួយរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង ០០២/០២ សហព្រះរាជអាជ្ញា បច្ចុប្បន្ននេះកំពុងតែរៀបចំពាក្យសុំតាមវិធានផ្ទៃក្នុង ៨៧(៤)ទាក់ទងនឹងសាក្សីចូលរួមសវនាការ ដែលមិនត្រូវបានបង្ហាញអត្តសញ្ញាណនៅមុនពេលសវនាការបឋមខែ មិថុនា ឆ្នាំ ២០១១ នៅក្នុងសំណុំរឿង ០០២/០១។ នៅក្នុងសំណើ សហព្រះរាជអាជ្ញាអន្តរជាតិ កត់សម្គាល់ថា ដីកាសម្រេចមុនរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិត្រង់ចំណុចដែលថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនទាន់ត្រៀមរួចរាល់ដើម្បីពិចារណាលើការបង្ហាញទាំងស្រុងនូវការស្តាប់ចម្លើយសំណុំរឿង ០០៤ ដែលពាក់ព័ន្ធនឹងសាក្សីបែបនោះ (“ដីកាសម្រេចមុន”)[5]។ ទោះយ៉ាងណា សហព្រះរាជអាជ្ញាអន្តរជាតិ ស្នើសុំការអនុញ្ញាតពីសហចៅក្រមស៊ើបអង្កេត ឲ្យបង្ហាញឯកសារក្នុងចំនួនមានកំណត់ គឺ៖

- បង្ហាញជូនអង្គជំនុំជម្រះសាលាដំបូង និងភាគីនានានៅក្នុងសំណុំរឿង ០០២/០២ នូវអង្គហេតុដែលថា សាក្សីចូលរួមសវនាការដែលបានស្នើចំនួន ៨ នាក់ដោយសហព្រះរាជអាជ្ញានៅក្នុងសំណុំរឿង ០០២/០២ (“សាក្សីទាំង ៨ នាក់”) គឺត្រូវបានជ្រើសរើស មួយផ្នែកដោយសារថាមានព័ត៌មានថ្មីនៅក្នុងការស្តាប់ចម្លើយបុគ្គលជាសាក្សីទាំងនោះនៅក្នុងសំណុំរឿង ០០៤ និងមានសេចក្តីសង្ខេបអំពីភស្តុតាងនោះ[6]។

---

[4] សំណុំរឿង ០០៤ ឯកសារ D200 *សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំបង្ហាញនៅក្នុងសំណុំរឿង ០០២/០២ នូវអត្តសញ្ញាណរបស់សាក្សីមួយចំនួនដែលត្រូវបានស្តាប់ចម្លើយនៅក្នុងសំណុំរឿង ០០៤* ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១៤។

[5] សំណុំរឿង ០០៤ ឯកសារ D193/1 *ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំបង្ហាញកំណត់ហេតុនៃការស្តាប់ចម្លើយសំណុំរឿង ០០៤ ដែលពាក់ព័ន្ធនឹងសំណុំរឿង០០២/២* ថ្ងៃទី ៨ ខែ ឧសភា ឆ្នាំ ២០១៤។

[6] សាក្សីទាំង ៨ នាក់ គឺ នាង អ៊ូច ហៅ សាន (កំណត់ហេតុនៃការស្តាប់ចម្លើយ D119/82 និង D118/172), អ៊ុល ហឿន (មជ្ឈមណ្ឌលឯកសារកម្ពុជា បទសម្ភាសន៍ D119/70/4 កំណត់ហេតុនៃការស្តាប់ចម្លើយ D118/208 និង D118/209), ឈុំ សេង (មជ្ឈមណ្ឌលឯកសារកម្ពុជា បទសម្ភាសន៍ D67.5 កំណត់ហេតុនៃការស្តាប់ចម្លើយ D119/89); ប៉ាន ឈួង (មជ្ឈមណ្ឌលឯកសារកម្ពុជា បទសម្ភាសន៍ D67.6); កំណត់ហេតុនៃការស្តាប់ចម្លើយ D61 និង D119/29); វៀល សន (កំណត់

01002627



- ឬក៏បង្ហាញជូនអង្គជំនុំជម្រះសាលាដំបូងនូវអត្តសញ្ញាណរបស់សាក្សីទាំងនោះតែក្នុងលក្ខខណ្ឌ *ភាគីតែម្ខាង* និងសម្ងាត់បំផុត និង

- ផ្តល់អាទិភាពដំបូងដោយបង្ហាញការស្តាប់ចម្លើយដែលពាក់ព័ន្ធនឹងសាក្សីទាំង ៨ នាក់ នៅពេលណា ដូចជា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ អាចសម្រេចលើការបង្ហាញឯកសារទាំងនោះ ព្រមទាំងបង្ហាញការស្តាប់ចម្លើយសាក្សីចូលរួមសវនាការ ដែលបានស្នើចំនួន ២ នាក់ផ្សេងទៀតដែលបច្ចុប្បន្ននេះ សហព្រះរាជអាជ្ញា បានបង្ហាញឈ្មោះក្លែងក្លាយ ពីព្រោះថា សាក្សីទាំងនេះមិនមានចម្លើយនៅក្នុងសំណុំរឿង ០០២ ទេ ហើយអត្តសញ្ញាណរបស់ពួកគាត់ត្រូវបានស្គាល់ និងបង្ហាញតែតាមរយៈការស្តាប់ចម្លើយពួកគាត់នៅក្នុងសំណុំរឿង ០០៤ តែប៉ុណ្ណោះ[7]។

## ពិភាក្សា

២. នៅថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៤ នៅក្នុងការឆ្លើយតបដំបូងទៅនឹងសំណើ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានសម្រេចដូចជា "*ពិនិត្យមើលកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីទាំង ៨ នាក់នៅក្នុងសំណុំរឿង ០០៤ ដើម្បីកំណត់ថាតើអនុញ្ញាត ឬក៏មិនអនុញ្ញាតឱ្យបង្ហាញឯកសារសម្ងាត់អំពីអត្តសញ្ញាណរបស់ពួកគាត់ និងការពិពណ៌នាទូទៅអំពីភស្តុតាងរបស់ពួកគាត់ជូនអង្គជំនុំជម្រះសាលាដំបូង និងភាគីនានានៅក្នុងសំណុំរឿង ០០២/២*"[8]។

---

ហេតុនៃការស្តាប់ចម្លើយ D118/181); ទឹម ហ៊ី ហៅ ទឹម ហ៊ី (កំណត់ហេតុនៃការស្តាប់ចម្លើយ D118/166); ពៅ ស៊ីនួន (កំណត់ហេតុនៃការស្តាប់ចម្លើយD118/127); ញឹម កុល ហៅ សយ(Say) (កំណត់ហេតុនៃការស្តាប់ចម្លើយ D117/32) ។

[7] សាក្សី ទាត់ ធឿន (កំណត់ហេតុនៃការស្តាប់ចម្លើយ D118/102, D118/154 និងD118/154.1) និង យូ វ៉ាន់ (កំណត់ហេតុនៃការស្តាប់ចម្លើយ D117/31)។

[8] សំណុំរឿង ០០៣ ឯកសារ D200/1 *ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំបង្ហាញនៅក្នុងសំណុំរឿង ០០២/០២ នូវអត្តសញ្ញាណរបស់សាក្សីមួយចំនួនដែលត្រូវបានស្តាប់ចម្លើយនៅក្នុងសំណុំរឿង ០០៤* ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៤ កថាខណ្ឌ ៦។

01002628



៣. នៅថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០១៤ នៅក្នុងការឆ្លើយតទៅនឹងសំណើពីសហចៅក្រមស៊ើបអង្កេតអន្តរជាតិ[9] សហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់សេចក្តីព្រាងសេចក្តីសង្ខេបអំពីភស្តុតាងដែលបុគ្គលទាំងនោះបានផ្តល់ជូននៅក្នុងសំណុំរឿង ០០៤ ហើយសហព្រះរាជអាជ្ញាអន្តរជាតិ មានបំណងស្នើទៅអង្គជំនុំជម្រះសាលាដំបូង ដើម្បីឲ្យបុគ្គលទាំងនោះធ្វើជាសាក្សីនៅក្នុងសំណុំរឿង ០០២/២។ សហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់សេចក្តីសង្ខេបទាំងនេះដោយផ្អែកលើមូលដ្ឋានត្រូវរក្សាការសម្ងាត់បំផុត និង*ភាគីតែម្ខាង*(“ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ”)[10]។ ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ រួមមានសេចក្តីសង្ខេងអំពីសាក្សីបន្ថែមម្នាក់ទៀតនៅក្នុងសំណុំរឿង ០០៤ គឺ ហែម មឿន ដោយភស្តុតាងរបស់គាត់សហព្រះរាជអាជ្ញាអន្តរជាតិ មិនបានស្នើសុំការអនុញ្ញាតឲ្យបង្ហាញនៅក្នុងសំណើ(“សំណើបន្ថែម”)។ សហព្រះរាជអាជ្ញាអន្តរជាតិ ស្នើសុំបង្ហាញភស្តុតាងរបស់ហែម មឿន ជូនអង្គជំនុំជម្រះសាលាដំបូង ក្នុងរបៀបដូចគ្នានឹងសាក្សីដទៃទៀតដែរ (“សេចក្តីសង្ខេប”)[11]។

៤. បន្ទាប់ពីពិនិត្យមើលសេចក្តីសង្ខេប សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ពិចារណាថា ព័ត៌មានដែលបានបង្ហាញនៅក្នុងកថាខណ្ឌ ១២(ក), (ខ) និង(គ)នៃសំណើ អាចបង្ហាញជូនអង្គជំនុំជម្រះសាលាដំបូង និងភាគីនានានៅក្នុងសំណុំរឿង ០០២/២ ទាក់ទងនឹងសាក្សីទាំង ៨ នាក់ និងហែម មឿន លើកលែងតែករណីដូចមានបញ្ជាក់ខាងក្រោម៖

- ទាក់ទងនឹងសាក្សី ញឹម កុល ហៅ សាយ(Say) ដោយអនុវត្តតាមសេចក្តីសម្រេចមុនរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ[12] និងដើម្បីការពារសុចរិតភាពនៃការស៊ើបអង្កេតដែលកំពុងបន្តដំណើរការ និងធានាសុវត្ថិភាពរបស់ជនរងគ្រោះ និងសាក្សីនៅ

---

[9] សំណុំរឿង ០០៤ ឯកសារ D200/2 *ដីកាសម្រេចទីពីរលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំបង្ហាញនៅក្នុងសំណុំរឿង ០០២/២នូវអត្តសញ្ញាណរបស់សាក្សីមួយចំនួនដែលត្រូវបានស្តាប់ចម្លើយ* ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៤ កថាខណ្ឌ ៥។

[10] សំណុំរឿង 004 ឯកសារ D200/3.1 *ចម្លើយតបដោយភាគីខែម្ខាងរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសំណើសុំសេចក្តីព្រាងសេចក្តីសង្ខេបរបស់របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ឧបសម្ព័ន្ធ I៖ សេចក្តីព្រាងសេចក្តីសង្ខេប* ថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០១៤។

[11] *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* កថាខណ្ឌ ៥។

[12] សំណុំរឿង 004 ឯកសារ D167/1 *សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំបង្ហាញឯកសារនៅក្នុងសំណុំរឿង ០០២* ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៣ កថាខណ្ឌ ៦។

ក្នុងសំណុំរឿង ០០៤ មានតែអង្គជំនុំជម្រះសាលាដំបូងប៉ុណ្ណោះដែលអាចត្រូវបានការជូនដំណឹងអំពីអត្តសញ្ញាណរបស់សាក្សីទាំងនេះ ដោយផ្អែកលើមូលដ្ឋានត្រូវរក្សាការសម្ងាត់បំផុត និង*ភាគីតែម្ខាង*។ មានតែសំណៅកោសលុបនៃសេចក្តីសង្ខេបរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីពីភស្តុតាងរបស់សាក្សីទាំងនោះតែប៉ុណ្ណោះដែលអាចបង្ហាញជូនភាគីនានា ដូចបានបង្ហាញនៅក្នុងកថាខណ្ឌ ៧ នៃសេចក្តីសង្ខេបដែលបានភ្ជាប់ជាឧបសម្ព័ន្ធ។

- ដូចបានបញ្ជាក់នៅក្នុងដីកាសម្រេចពាក់ព័ន្ធដែលបានចេញនៅក្នុងសំណុំរឿង០០៣[13] សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ពិចារណាថា វាមិនសមស្របដែលត្រូវបង្ហាញព័ត៌មានបន្ថែមទៀតជូនភាគីនានានៅក្នុងសំណុំរឿង ០០២ រហូតទាល់តែ កិច្ចស៊ើបសួរទាំងអស់ទាក់ទងនឹងសាក្សីសក្តានុពលឈ្មោះ ម៉ា ឈឿន បានបញ្ចប់សព្វគ្រប់។ អាស្រ័យហេតុនេះ ដោយផ្អែកលើមូលដ្ឋានត្រូវរក្សាការសម្ងាត់បំផុត និង*ភាគីតែម្ខាង* មានតែអង្គជំនុំជម្រះសាលាដំបូងប៉ុណ្ណោះដែលអាចត្រូវបានការជូនដំណឹងអំពីសេចក្តីសង្ខេបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ស្តីពីសាក្សីរូបនេះ និងអំពីអង្គហេតុដែលថា សហព្រះរាជអាជ្ញា បានដឹងអំពីភស្តុតាងនេះនៅពេលដែលចម្លើយពីការសម្ភាសរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា បានដាក់ចូលក្នុងសំណុំរឿង ០០៣។

**តាមសំអាងហេតុខាងលើ ខ្ញុំ MARK B. HARMON ៖**

៥. **ផ្តល់ការអនុញ្ញាតខ្លះតាម**សំណើទាក់ទងនឹងសាក្សីញឹម កុល ហៅ សយ និង ម៉ា ឈឿន ដូចបានបញ្ជាក់នៅក្នុងកថាខណ្ឌ ៤ ខាងលើ។

៦. **អនុញ្ញាតតាម**ផ្នែកផ្សេងទៀតទាំងអស់នៃសំណើ និងសំណើបន្ថែម។

៧. **សម្រេច**ផ្តល់អាទិភាពដំបូងដោយបង្ហាញភស្តុតាងដែលមានស្រាប់នេះ និងការស្តាប់ចម្លើយណាមួយនាពេលអនាគតដែលពាក់ព័ន្ធនឹងសាក្សីទាំង ៨ នាក់ ព្រមទាំងការស្តាប់ចម្លើយសាក្សី

---

[13] សំណុំរឿង ០០៣ ឯកសារ D106/4 *ដីកាសម្រេចទីបីលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំបង្ហាញនៅក្នុងសំណុំរឿង០០២/២ នូវព័ត៌មានទាក់ទងនឹងចម្លើយរបស់សាក្សីពីរនាក់ និងដើមបណ្តឹងរដ្ឋប្បវេណីម្នាក់នៅក្នុងសំណុំរឿង ០០៣* ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១៤ កថាខណ្ឌ ៥។

ពីរនាក់បន្ថែមទៀតដែលបានលើកឃោងនៅក្នុងកថាខណ្ឌ ១១ នៃសំណើ និងសាក្សីបន្ថែមម្នាក់ទៀតដែលជាកម្មវត្ថុនៃសំណើបន្ថែម នៅពេលណាមួយ ដូចជា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានត្រៀមរួចរាល់ដើម្បីពិចារណាលើការបង្ហាញទាំងស្រុងនូវការសម្ពាប់ចម្លើយសំណុំរឿង ០០៤ ដែលបានស្នើសុំពីមុន[14]។

ភ្នំពេញ ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១៤

**ចៅក្រម Mark B. Harmon**

**សហចៅក្រមស៊ើបអង្កេតអន្តរជាតិ**

**International Co- Investigating Judge**

**Co-juge d'instruction International**

[14]សំណុំរឿង ០០៤ ឯកសារ D193/1 *ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំបង្ហាញកំណត់ហេតុនៃការស្តាប់ចម្លើយសំណុំរឿង ០០៤ ដែលពាក់ព័ន្ធនឹងសំណុំរឿង០០២/២* ថ្ងៃទី ៨ ខែ ឧសភា ឆ្នាំ ២០១៤។